# សួស្តីឆ្នាំថ្មី!

ក្នុងឱកាសចូលឆ្នាំថ្មីនេះ ខ្ញុំសូមបន់ស្រន់បួងសួងដល់ទេវតាទាំង ១ ម៉ឺនលោកធាតុ ព្រមទាំងវត្ថុស័ក្តិសិទ្ធ ទាំងឡាយនៅក្នុងចក្រវាលទាំងមូល សូមថែរក្សាការពារ ជូនពរជ័យ សិរីមង្គលគ្រប់ប្រការ ចូរកើតមានដល់គ្រួសារខ្មែរទាំងអស់គ្រប់គ្នា។ សូមអោយរួចចាកផុតពីទុក្ខភ័យអពមង្គលទាំងឡាយ អោយ ចៀសចាកចេញឆ្ងាយពីស្រុកខ្មែរយើង។ សូមអោយគ្រួសារខ្មែរទាំងអស់បានសេចក្តីសុខគ្រប់ៗគ្នាកុំបីឃ្លាងឃ្លាតឡើយ។




ជាពិសេសឆ្នាំនេះ ខែចូលឆ្នាំ ខែមេសា នឹកឡើងកាលណាខែមេសា ជាពិសេស អនុស្សាវរីយ ដ៏ខ្លោចផ្សាគ្មានអ្វីផ្ទឹមរបស់ថ្ងៃ ១៧ មេសា កាលពី ៣៥ ឆ្នាំកន្លងទៅនេះ។ ១៧ មេសា គឺជាសោកនាដកម្ម គឺជាថ្ងៃអពមង្គលអន្តរធានពេលដែលខ្មែរក្រហមបិសាច ចូលមកកាប់សំឡាប់ ដែលអ្នកខ្លះនៅតែហៅថាថ្ងៃ ជ័យជំនះនោះ។ ខ្ញុំរំលឹករឿងនេះដោយហេតុថា ខ្ញុំចង់បន់ស្រន់អោយអ្នកដឹកនាំខ្មែរ ទាំងតូចទាំងធំ ទាំងថ្នាក់កំពូល និយាយអោយចំទៅ អោយខ្មែររៀនទទួលខុសត្រូវ ដោយហ៊ាននិយាយការពិតអោយអស់ពីពោះពីពុង បើខុសអោយហ៊ានថាខុស បើត្រូវអោយហ៊ានថាត្រូវ កុំខ្មាសអៀន ទើបយើងបានចំជាអ្នកដែលធ្វើការទទួល ខុស ត្រូវ លើសុខទុក្ខរបស់រាស្ត្រខ្មែរទាំងមូលមែនទែន។ ទោះជាទុក្ខអន្តរាយនោះវាកើតមានដល់អ្នកដែលជំទាស់នឹងយើងក៏ដោយ ពីព្រោះ មុខងាររបស់អ្នកដឹកនាំ គឺទទួលខុសត្រូវរកសុខអោយខ្មែរទាំងអស់ មិនថាខ្មែរស្រលាញ់រួមខាងយើងទេ រួមទាំងខ្មែរអ្នកដែលជំទាស់នឹងយើងផង។

៣៥ ឆ្នាំ បានកន្លងផុតមកហើយ គោលបំណងរបស់ខ្ញុំ សុំបន់ស្រន់អោយខ្មែរទាំងអស់ហ៊ាននិយាយសុំទោសបើឃើញ ដឹងថាខុស ទើបអាចអោយយើងបានរីកចម្រើនទៅមុខទាំងអស់គ្នាបាន។

## អបអរសាទរពរឆ្នាំថ្មី!

ពីអ្នកជា កាពិតម្ទេសខ្មាំង